រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០០

## សេចក្ដីសំរេច ១០ សសរ.

## ស្ដីពី ការបង្កើតគណៈកម្មការអន្តរក្រសួង កំណត់ព្រំប្រទល់ដែនឡូត៍នេសាទ ខេត្តសៀមរាប

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

-យោងតាមការងារចាំបាច់ និងបន្ទាន់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងកំណត់ព្រំប្រទល់ដែនឡូត៍នេសាទ ខេត្តសៀមរាប ដែលរួមមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម ម៉ៅ សំអឿន | រដ្ឋលេខាធិការ ក្រសួង រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-ឯកឧត្តម ម៉ុល លឹម | អគ្គាធិការរង ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-ឯកឧត្តម ឡាយ វិរិទ្ធិសិដ្ឋ | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ៤-ឯកឧត្តម សំ សារិន | អនុរដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៥-ឯកឧត្តម ឡែ សារិន | អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦-ឯកឧត្តម ម៉ុន សំ | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-លោក ស៊ុយ សាន | អភិបាលរងទី២ ខេត្តសៀមរាប | សមាជិក |
| ៨-លោក ឈៅ ធូក | អនុប្រធាននាយកដ្ឋានជលផល | លេខាធិការ |

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះមានភារកិច្ច :

១-ចុះត្រួតពិនិត្យ និងស្រាវជ្រាវ និងកំណត់អោយបានច្បាស់លាស់ អំពី :

-លក្ខខណៈភូមិសាស្ត្រ នៃព្រំប្រទល់ដែនឡូត៍នេសាទនីមួយៗ

-ព្រំប្រទល់ភូមិឋានរបស់ប្រជារាស្ត្រដែលរស់នៅយូរមកហើយ និងទើបមកតាំងនៅថ្មី

២-ធ្វើរបាយការណ៍ជាអចិន្ត្រៃយ៍ពីលទ្ធផលត្រួតពិនិត្យ និងស្នើវិធានការដោះស្រាយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**ប្រការ ៣ :** សមាជិកគណៈកម្មការអន្តរក្រសួងត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧត្តុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តសៀមរាប និងសមាសភាពដូចមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តន៍ សេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ស ខេង

***

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០០

## សេចក្តីសំរេច ១១ សសរ

## ស្តីពី ការបង្កើតគណៈកម្មការចំរុះ ដោះស្រាយបញ្ហាដីធ្លី និងគ្រួសារប្រជាជនស្នាក់នៅបរិវេណអតីត ម៉ូតែលសុខា ក្រុងព្រះសីហនុ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងសេចក្តីជូនដំណឹង របស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៦១២ សជណ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ១៩៩៦ ស្តីពីការអនុញ្ញាតអោយក្រសួងទេសចរណ៍ បានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនវិនិយោគទុន សូគីម៉ិចកម្ពុជា